**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Aug-2011, 13:40
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**
ចំណាត់ថ្នាក់ប្រភេទឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

# សេចក្តីសង្ខេបរបស់ អៀង សារី នៅលើការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញានៅនឹងចម្លើយតបនានារបស់មេធាវីការពារក្តីលើសំណើ របស់សហព្រះរាជអាជ្ញាសុំឲ្យកំណត់បទចោទជាថ្មីឡើងវិញក្នុងដីកាដំណោះស្រាយ និងដកលក្ខខណ្ឌ តម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

---

**<u>ដាក់ដោយ:</u>**

**សហមេធាវី:**

អាង ឧត្តម
Michael G. KARNAVAS

**<u>អង្គជំនុំជម្រះសាលាដំបូង:</u>**

ចៅក្រម **និល ណុន** ប្រធាន
ចៅក្រម **ធូ មណី**
ចៅក្រម **យ៉ា សុខន**
ចៅក្រម Silvia CARTWRIGHT
ចៅក្រម Jean-Marc LAVERGNE

---

ចៅក្រមបម្រុង **យូរ ឧត្តរា**

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់ខ្លួន (“មេធាវីការពារក្តី”) សូមដាក់សេចក្តីសង្កេតទាំងនេះ ទៅនឹងការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបនានារបស់មេធាវីការពារក្តីលើសំណើរបស់សហព្រះរាជអាជ្ញា[១] សុំឱ្យកំណត់បទចោទជាថ្មីឡើងវិញក្នុងដីកាដំណោះស្រាយ និងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (“សារណាតប”)[២]។ សេចក្តីសន្និដ្ឋានទាំងនេះមានលក្ខណៈចាំបាច់ណាស់ ពីព្រោះសារណាតប រួមមានការលើកឡើងមិនត្រឹមត្រូវ ការលើកឡើងដោយភ័ន្តច្រឡំ និងការកំណត់អង្គហេតុនិងអង្គច្បាប់មិនត្រឹមត្រូវមួយចំនួន។ សេចក្តីសន្និដ្ឋានទាំងនេះធ្វើឡើងដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូង និងកម្រិតត្រឹមការឆ្លើយតបទៅនឹងការលើកឡើងមិនត្រឹមត្រូវ ការលើកឡើងដោយភ័ន្តច្រឡំ និងការកំណត់អង្គហេតុនិងអង្គច្បាប់មិនត្រឹមត្រូវទាំងនេះប៉ុណ្ណោះ។ ដើម្បីជាផលប្រយោជន៍យុត្តិធម៌ វាតម្រូវឱ្យមេធាវីការពារក្តីជម្រាបដល់អង្គជំនុំជម្រះសាលាដំបូងឱ្យដឹងជាមុនអំពី ការលើកឡើងមិនត្រឹមត្រូវ ការលើកឡើងដោយភ័ន្តច្រឡំ និងការកំណត់អង្គហេតុនិងអង្គច្បាប់មិនត្រឹមត្រូវទាំងនេះ ដោយសារតែ ក.ស.ព បានលើកឡើងថា មិនគួរមានសវនាការសួរដេញដោលផ្ទាល់មាត់ទៅលើបញ្ហាទាំងនេះឡើង និងដោយពិចារណាលើលទ្ធភាពដែលថានឹងមិនអាចមានសវនាការសួរដេញដោលផ្ទាល់មាត់នោះ។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានទទួលយក និងដាក់សេចក្តីសន្និដ្ឋាននានារបស់ ក.ស.ព ទៅក្នុងសំណុំរឿងរួចហើយ[៣]។

---

[១] សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E99 (“សំណើរបស់ ក.ស.ព ស្តីពីបទរំលោភសេពសន្ថវៈ”)។ សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E95 (“សំណើរបស់ ក.ស.ព ស្តីពីជម្លោះប្រដាប់អាវុធ”)។ សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ III ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រោះម្យ៉ាងទៀត, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E100 (“សំណើរបស់ ក.ស.ព ស្តីពីសហឧក្រិដ្ឋកម្មរួម”) (រួមបញ្ចូលគ្នាទាំងអស់គឺហៅថា “សំណើរបស់ ក.ស.ព”)។

[២] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបនានារបស់មេធាវីការពារក្តីលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកំណត់បទចោទជាថ្មីឡើងវិញក្នុងដីកាដំណោះស្រាយ និងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១១, ឯកសារ E95/6។

[៣] *សូមមើលជាឧទាហរណ៍,* សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាលើសំណើបន្ទាន់របស់មេធាវីការពារក្តីរបស់អៀង ធីរិទ្ធ និង នួន ជា សុំឱ្យបញ្ជាក់ថ្ងៃផុតកំណត់, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១១, ឯកសារ E14/1។ សេចក្តីសង្កេតរបស់

## ក. ភាពអាចទទួលយកបាននៃសំណើរបស់ ក.ស.៣

១. កថាខណ្ឌ ១៩

***អំណះអំណាងរបស់ ក.ស.៣៖*** មេធាវីការពារក្តី "បានទទួលស្តាប់" ក្នុងអំឡុងពេលនៃសវនាការបឋម ថា បញ្ហាស្តីពីថាតើ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនឹងត្រូវយកមកអនុវត្តត្រឹមកម្រិតណានោះ គឺ "មិនចាំបាច់" ជាបញ្ហាទាក់ទងនឹងយុត្តាធិការនោះទេ ទោះបីជា "ការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជា "បញ្ហាទាក់ទិននឹងយុត្តាធិការ" ដែលស្ថិតនៅក្នុងវិសាលភាពនៃវិធាន ៨៩ យ៉ាងណាក៏ដោយ"។

***សេចក្តីសង្កេត៖*** នេះគឺជាការកំណត់អំពីគោលជំហររបស់មេធាវីការពារក្តីដោយមិនត្រឹមត្រូវ។

សហមេធាវីការពារក្តី Michael G. Karnavas បានបញ្ជាក់ច្បាស់ថា ៖

> ខ្ញុំគិតថា [អញ្ញត្រកម្មរបស់មេធាវីការពារក្តី ដែលមិនត្រូវបានគេគ្រោងក្នុងអំឡុងសវនាការបឋមដើម្បីស្តាប់] ទាំងនេះ ស្ថិតនៅក្នុងក្រោមបញ្ហានៃយុត្តាធិការ។ ដូច្នេះហើយបានជាយើងខ្ញុំគិតថា យើងអាច ឬក៏យើងគួរ ខ្ញុំគិតថាយើងគួរតែស្តាប់អំពីបញ្ហាយុត្តាធិការនេះ បើទោះជាទាក់ទិនទៅនឹង វិធាន៨៩(១)(ក) និង ៨៩(១)(ខ)។ ប៉ុន្តែ បើទោះបីជា អង្គជំនុំជម្រះនឹងអាចយល់ឃើញថា បញ្ហាទាំងអស់ នេះមិនមែនជាបញ្ហាដែលចាំបាច់ស្ថិតនៅក្នុងបញ្ហាយុត្តាធិការក៏ដោយ ហើយថាតើបញ្ហានេះ យើងអាចយកទៅអនុវត្ត ឬក៏ថាស្ថិតនៅក្នុងកម្រិតណាដែលចំណុចនេះអាចយកទៅអនុវត្តបាននោះ គឺថា ខ្ញុំគិតថានេះគឺជា បញ្ហាទាំងឡាយដែលយើងចាំបាច់ត្រូវធ្វើការដោះស្រាយ មុនពេលយើងចាប់ផ្តើមសវនាការលើអង្គសេចក្តី។ ហើយពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម ជេ.ស៊ី.អ៊ី នេះ ជាពិសេសទម្រង់ទីបីនៃ ជេ.ស៊ី.អ៊ី គឺយើងខ្ញុំសូមស្នើជូន ទៅអង្គជំនុំជម្រះថា នេះគឺជាបញ្ហាយុត្តាធិការសុទ្ធសាធ យើងមិននិយាយអំពីបញ្ហាអ្វីផ្សេងទៀតទេ។ ពីព្រោះថាទម្រង់ទីបីនៃ ជេ.ស៊ី.អ៊ី គឺជាទម្រង់មួយដែលថា សកម្មភាពហ្នឹងវាអាចមិននៅក្រោមច្បាប់ទំនៀមអន្តរជាតិទេ ហើយក៏វាមិនស្ថិតនៅក្រោមយុត្តាធិការពេលវេលារបស់តុលាការយើង

---

សហព្រះរាជអាជ្ញា ទៅលើញត្តិរបស់ អៀង សារី សុំការណែនាំអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី, ថ្ងៃទី៤ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារ E23/1។ សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា លើសំណើរបស់ អៀង ធីរិទ្ធ ស្នើសុំឱ្យមានការបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់អញ្ញត្រកម្ម, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១, ឯកសារ E24/1។

សព្វថ្ងៃនេះដែរ។ ហើយ ដូច្នេះ ភាគីមានរយៈពេល ៣០ថ្ងៃ នៅក្នុងការដាក់នូវឯកសារទាក់ទងទៅនឹងបញ្ហាយុត្តាធិការនេះ។ អយ្យការមិនបានរៀបចំនៅក្នុងការឆ្លើយតបទៅលើបញ្ហានេះទេ”[៤]។

នៅក្នុងបរិបទ សេចក្តីបញ្ជាក់របស់សហមេធាវី Karnavas បង្ហាញថា គោលជំហរសំខាន់របស់មេធាវីការពារក្តីគឺថា បញ្ហាទាក់ទិននឹងអត្ថិភាពនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬធាតុផ្សំមួយចំនួន (ឧទាហរណ៍គោលដៅនិងគោលបំណង) នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គួរត្រូវបានចាត់ទុកថាជាបញ្ហា នៃយុត្តាធិការ អនុលោមតាមវិធាន ៨៩។ ក្នុងជម្រើសម្យ៉ាងទៀត សហមេធាវី Karnavas បានលើកទឡ្ហីករណ៍ថា ទោះបីជា អង្គជំនុំជម្រះនឹងអាចយល់ឃើញថា បញ្ហាទាំងអស់នេះមិនមែនជាបញ្ហាដែលចាំបាច់ស្ថិតនៅក្នុងបញ្ហាយុត្តាធិការក៏ដោយ ក៏បញ្ហាទាំងនេះ ចាំបាច់ត្រូវធ្វើការដោះស្រាយ មុនពេលយើងចាប់ផ្តើមសវនាការលើអង្គសេចក្តី។ គេអាចមើលឃើញច្បាស់នូវគោលជំហររបស់មេធាវីការពារក្តី តាមរយៈការពិនិត្យឡើងវិញលើខ្លឹមសារទាំងមូលនៃការលើកឡើងរបស់សហមេធាវី Karnavas ជាជាងគ្រាន់តែពិនិត្យមើលទៅលើឃ្លាសម្រង់ព្រមទាំងសេចក្តីសន្និដ្ឋានពីមុនៗរបស់សហមេធាវីការពារក្តី[5]។

២. កថាខណ្ឌ ២០

***អំណះអំណាងរបស់ ក.ស.ព*** ៖ “ប្រសិនបើរាល់សំណើសុំឱ្យកំណត់បទចោទឡើងវិញទាំងអស់ត្រូវបានចាត់ទុកថាជាអញ្ញត្រកម្មបឋមស្តីពីយុត្តាធិការនោះ វិធាន៨៨(២) នៃវិធានផ្ទៃក្នុងដែលអនុញ្ញាតឱ្យកំណត់បទចោទឡើងវិញ មុខជានឹងគ្មានន័យទៅហើយ”។

***សេចក្តីសង្កេត*** ៖ នេះគឺជាការលើកឡើងមិនត្រឹមត្រូវ។

ពុំមែនរាល់សំណើសុំឱ្យកំណត់បទចោទឡើងវិញទាំងអស់ ដែលស្ថិតនៅក្រោមវិធាន៩៨(២) គឺជាបញ្ហានៃយុត្តាធិការឡើយ។ ឧទាហរណ៍ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អង្គជំនុំជម្រះមានយុត្តាធិការទៅលើ ឧក្រិដ្ឋកម្មអន្តរជាតិ និងឧក្រិដ្ឋកម្មជាតិ អង្គជំនុំជម្រះអាចពិចារណាលើសំណើ អនុលោមតាមវិធាន ៩៨(២) ដែលថា អង្គហេតុមួយចំនួនគួរត្រូវបានកំណត់បទចោទឡើងវិញជាអំពើមនុស្សឃាត ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជំនួសឱ្យអំពើមនុស្សឃាត

---

[៤] ប្រតិចារឹក, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E1/7.1, ទំព័រ ៤០-៤១។

[៥] *សូមមើលជាឧទាហរណ៍,* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០, ឯកសារ D427/1/6, កថាខណ្ឌ ១៨៤-២៣១។

ជាឧក្រិដ្ឋកម្មជាតិ[៦]។ ទោះបីជាយ៉ាងណាក៏ដោយ សំណើ ដែលជំទាស់ទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវតែលើកឡើងជាអញ្ញត្រកម្ម អនុលោមតាមវិធាន ៨៩។

៣. **កថាខណ្ឌ ២១**

***អំណះអំណាងរបស់ ក.ស.ព*** ៖ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចហើយនៅក្នុងករណីរបស់ *ឌុច* ថា សំណើទាំងឡាយដែលសុំឲ្យកំណត់បទចោទឡើងវិញ គឺវាមិនមែនជាអញ្ញត្រកម្មបឋម ដែលស្ថិតក្រោមវិធាន ៨៩ នោះឡើយ។

***សេចក្តីសង្កេត*** *៖* នេះគឺជាការកំណត់សាលក្រមក្នុងរឿងក្តី *ឌុច* ដោយមិនត្រឹមត្រូវ

អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ឌុច ពុំបានសម្រេចបែបនេះឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះថា ៖ "នៅក្នុងអំឡុងពេលសវនាការបឋម មិនមានការលើកឡើងអំពីអញ្ញត្រកម្មចំពោះយុត្តាធិការរបស់ អ.វ.ត.ក ផ្អែកតាមវិធាន៨៩ នៃវិធានផ្ទៃក្នុងទេ។ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល មេធាវីការពារក្តីបានលើកឡើងអំពីភាពមិនមានយុត្តាធិការរបស់អង្គជំនុំជម្រះ ដោយផ្អែកលើមូលហេតុថា ជនជាប់ចោទមិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬជាជនម្នាក់ក្នុងចំណោមជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ"[៧]។ អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែចង្អុលបង្ហាញថា មេធាវីការពារក្តី ឌុច មិនបានយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់ ដែលខកខានពុំបានលើកឡើងនូវបញ្ហាយុត្តាធិការឲ្យបានទាន់ពេលវេលា។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាដំបូងសំដៅទៅលើសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ពាក់ព័ន្ធនឹងយុត្តាធិការលើបុគ្គល ដែលធ្វើឡើងមិនបានទាន់ពេលវេលា និងមិនបានត្រឹមត្រូវជាលើកដំបូងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។ តាមពិត នេះគឺជាចំណុចសំខាន់ជាក់លាក់នៃទឡ្ហីករណ៍របស់មេធាវីការពារក្តី អៀង សារី ចំពោះថាតើហេតុអ្វីបានជាអង្គជំនុំជម្រះសាលាដំបូងគួរបដិសេធសំណើរបស់ ក.ស.ព សុំឲ្យកំណត់

---

[៦] ពុំមានចំណុចត្រង់ណានៅក្នុងកថាខណ្ឌនេះគួរត្រូវបានបកស្រាយថាជាការបោះបង់សិទ្ធិនៃអញ្ញត្រកម្មរបស់មេធាវីការពារក្តីចំពោះយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តអំពើមនុស្សឃាតជាឧក្រិដ្ឋកម្មជាតិ ឬអំពើមនុស្សឃាតជាឧក្រិដ្ឋកម្មអន្តរជាតិឡើយ។ ឧទាហរណ៍ដែលបានលើកឡើងនោះ គឺក្នុងគោលបំណងពន្យល់ប៉ុណ្ណោះ។

[៧] *សំណុំរឿង កាំង ហ្កេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អវតក/អជសដ, សាលក្រម, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០,ឯកសារ E188, កថាខណ្ឌ ១៤។

បទចោទឡើងវិញនោះ ៖ ក.ស.ព កំពុងតែលើកឡើងនូវបញ្ហា ដែលគួរតែបានលើកឡើងជាអញ្ញត្រកម្ម ដូច្នេះបញ្ហានេះត្រូវបានលើកឡើងមិនបានទាន់ពេលវេលានិងមិនបានត្រឹមត្រូវឡើយ។ ដូចដែលបានលើកទឡ្ហីករណ៍ពីមុនរួចហើយ[៨] ស្របគ្នាជាមួយនឹងអ្វីដែលទំនងជាការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ឌុច វិធានជាក់លាក់មួយត្រូវបានអនុម័តរួចហើយ ទាក់ទិននឹងការកំណត់ពេលវេលាចំពោះការជំទាស់ទៅនឹងយុត្តាធិការ ដូច្នេះ បញ្ហាទាំងនេះនឹងត្រូវបានដោះស្រាយមុនពេលចាប់ផ្តើមសវនាការលើអង្គសេចក្តី។ នេះគឺជាការកំណត់ដោយមិនត្រឹមត្រូវសម្រាប់ ក.ស.ព ដែលលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចហើយនៅក្នុងករណីរបស់ *ឌុច* ថា សំណើទាំងឡាយដែលសុំឲ្យកំណត់បទចោទឡើងវិញ គឺវាមិនមែនជាអញ្ញត្រកម្មបឋមឡើយ។

៤. **កថាខណ្ឌ ២២**

***<u>អំណះអំណាងរបស់ ក.ស.ព</u>*** ៖ ទោះបីជាសំណើនានារបស់សហព្រះរាជអាជ្ញា អាចត្រូវបានដាក់ក្នុងនាមជាអញ្ញត្រកម្មបឋម អនុលោមតាមវិធាន៨៩ ក៏ដោយ ក៏នេះមិនមែនជាការច្រានចោលជាមុន មិនឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណាទៅលើសំណើទាំងនោះនៅពេលបច្ចុប្បន្ននេះដែរ។

***<u>សេចក្តីសង្កេត</u>*** ៖ នេះគឺជាការលើកឡើងមិនត្រឹមត្រូវអំពីវិធាន។

ការអះអាងនេះ គឺមិនអើពើចំពោះលក្ខខណ្ឌតម្រូវយ៉ាងច្បាស់ក្រឡែតនៅក្នុងវិធាន ៨៩ ដែលថាបញ្ហាផ្នែកយុត្តាធិការ "<u>ត្រូវ</u>លើកឡើង<u>យ៉ាងយូរ</u> ៣០ (សាមសិប)ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ <u>បើមិនដូច្នេះទេ អញ្ញត្រកម្មនោះមិនអាចត្រូវបានទទួលយកឡើយ</u>"[៩]។

៥. កថាខណ្ឌ ២៦

---

[៨] *សូមមើល* ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ជាទម្រង់មួយទៀតនៃការទទួលខុសត្រូវ និងសំណើសុំឲ្យមានសវនាការផ្ទាល់មាត់ដើម្បីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ E100/2, កថាខណ្ឌ ៥-៦។

[៩] គូសបញ្ជាក់បន្ថែម។

***អំណះអំណាងរបស់ ក.ស.ព*** ៖ មេធាវីការពារក្ដីផ្ដាប់ "បានទទួលស្គាល់" ថា សិទ្ធិអំណាចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្លាស់ប្ដូរការកំណត់បទចោទ អាចបញ្ចូលការផ្លាស់ប្ដូរចំពោះទម្រង់នៃការទទួលខុសត្រូវជាធរមានផងដែរ ជាពិសេស សហឧក្រិដ្ឋកម្មរួម (JCE)។

***សេចក្ដីសង្កេត*** ៖ នេះគឺជាការកំណត់នូវគោលជំហររបស់មេធាវីការពារក្ដីមិនបានត្រឹមត្រូវ។ តាមពិត មេធាវីការពារក្ដីបញ្ជាក់ថា ៖

> នៅក្នុងកថាខណ្ឌទី១៦ និងទី១៧ ក.ស.ព អះអាងថា សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់ជនត្រូវចោទ នឹងមិនត្រូវបានរំលោភនោះឡើយ ពីព្រោះជនត្រូវចោទ "នឹងមានបុព្វហេតុ ដែលមានសុពលភាពក្នុងការរៀបចំនូវការជំទាស់ផ្នែកយុត្តាធិការ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង"។ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងអាចមាន "អំណាចក្នុងការកែប្រែការកំណត់លក្ខណៈផ្លូវច្បាប់នៃបទឧក្រិដ្ឋទាំងឡាយ" ត្រឹមដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនោះ ជាលទ្ធផលអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការដកហូតការទទួលខុសត្រូវពីលោក អៀង សារី ដើម្បីស្វែងរកប្រភេទនៃការការពារ និងការដោះបន្ទុក ដែលបច្ចុប្បន្ននេះរូបគាត់មានសិទ្ធិទទួលបាន។ ចំណុចនេះអាចអនុវត្តបានជាពិសេស (ដូចដែលបានជំទាស់ទៅនឹងលក្ខណៈជាទ្រឹស្ដី) ពាក់ព័ន្ធនឹងសិទ្ធិក្នុងការទទួលបាននូវ "ពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួន" ដូចមានចែងនៅក្នុងមាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") ដែលត្រូវបានច្របាច់បញ្ចូលគ្នាយ៉ាងជាក់លាក់នៅក្នុងមាត្រា ១៣ នៃកិច្ចព្រមព្រៀង"[១០]។

មេធាវីការពារក្ដីពុំបាន "ទទួលស្គាល់" ថា អង្គជំនុំជម្រះសាលាដំបូងអាចកំណត់អង្គហេតុឡើងវិញដើម្បីបញ្ចូលសហឧក្រិដ្ឋកម្មរួមទម្រង់ទី III បន្ទាប់ពីអង្គបុរេជំនុំជម្រះបានសម្រេចយ៉ាងច្បាស់រួចហើយថា អ.វ.ត.ក ពុំមានយុត្តាធិការដើម្បីអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ឡើយ ពីព្រោះសហឧក្រិដ្ឋកម្មទម្រង់ទី III ពុំមានអត្ថិភាពនៅក្នុងច្បាប់ជាធរមានក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ ឡើយ ហើយការទទួលខុសត្រូវប្រាកដជាមិនអាចប្រមើលដឹងជាមុនបានទេ។ មេធាវីការពារក្ដីគ្រាន់តែដកស្រង់វិធាន ៩៨(២) និងបានពន្យល់ថា ប្រការនេះមិនមែនជាបញ្ហាដែលត្រូវទុកចោលរហូតដល់បញ្ចប់ដំណើរការនីតិវិធីឡើយ។ មេធាវីការពារក្ដី បានពន្យល់ថា លទ្ធភាពនៃការបញ្ចូល

---

[១០] សារណារបស់លោក អៀង សារី ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ស្ដីពីសហកម្មឧក្រិដ្ឋកម្មរួម, ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០, ឯកសារ D97/14/14, កថាខណ្ឌ ១២ (គូសបញ្ជាក់បន្ថែម)។

ការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម តាមរយៈវិធាន ៨៩(២) នឹងដកហូតសិទ្ធិរបស់មេធាវីការពារក្តីមិនឲ្យលើកឡើងនូវបញ្ហានេះនៅដំណាក់កាលមុនជំនុំជម្រះក្តី ដោយបានធ្វើឲ្យសិទ្ធិនេះមិនមានន័យអ្វីឡើយ។ មេធាវីការពារក្តីមានជំហរដដែលមិនផ្លាស់ប្តូរឡើយ ទៅលើបញ្ហានេះ នៅក្នុងដំណាក់កាលមុនជំនុំជម្រះក្តី និងដំណាក់កាលជំនុំជម្រះក្តីនៃសំណុំរឿង ០០២។ ការពិនិត្យឡើងវិញនូវគោលជំហរទាំងមូលរបស់មេធាវីការពារក្តីលើបញ្ហានេះ អាចជួយដល់អង្គជំនុំជម្រះសាលាដំបូង[១១]។

៦. កថាខណ្ឌ ២៨

***អំណះអំណាងរបស់ ក.ស.ព*** ៖ ក.ស.ព ដឹងថា តុលាការកម្ពុជាតែងធ្វើការកែសម្រួលទៅលើការកំណត់ទម្រង់នៃការទទួលខុសត្រូវ ដោយផ្អែកលើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ដែល ក.ស.ព ទទួលស្គាល់ថាពុំមានចែងច្បាស់លាស់ចំពោះបញ្ហានេះឡើយ)។ អង្គជំនុំជម្រះសាលាដំបូងអាចចាប់យកការកត់សម្គាល់របស់តុលាការអំពី "ទម្លាប់នៃការអនុវត្តទៀតទាត់" បែបនេះ ដើម្បី ធ្វើជាអង្គហេតុបញ្ជាក់អំពីការដឹងឮជាទូទៅ។

***សេចក្តីសង្កេត*** ៖ នេះគឺជាការភ័ន្តច្រឡំ។ ក.ស.ព ពុំបានផ្តល់នូវការគាំទ្រដល់អំណះអំណាងរបស់ខ្លួនឡើយដែលថានេះគឺជាទម្លាប់នៃការអនុវត្តទៀតទាត់នោះ។ ក.ស.ព ក៏ខកខានផងដែរពុំបានទទួលស្គាល់ ឬលើកទឡ្ហីករណ៍ជំទាស់ទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអង្គជំនុំជម្រះមិនអាចធ្វើការកត់សម្គាល់នូវអង្គហេតុនៃការដឹងឮជាទូទៅបានឡើយ ដោយសារតែ "ពុំមានមូលដ្ឋានផ្លូវច្បាប់ឡើយនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬនៅក្នុងវិធានផ្ទៃក្នុង

---

[១១] ក្រៅពីសារណា ដែលថ្មីៗនេះមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង សារណាពាក់ព័ន្ធនានារួមមាន៖ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស អំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជា សហកម្មឧក្រិដ្ឋកម្មរួម, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១០, ឯកសារ D97/14/5, និង សារណារបស់លោក អៀង សារី ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០, ឯកសារ D97/14/14។

សម្រាប់ឲ្យអង្គជំនុំជម្រះធ្វើការកត់សម្គាល់នូវអង្គហេតុដែលបានវិនិច្ឆ័យរួចហើយ ឬអង្គហេតុនៃការដឹងឮជាទូទៅយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក នោះទេ..."[១២]។

## ខ. សំណើរបស់ ក.ស.ព ស្តីពីបទរំលោភសេពសន្ថវៈ

៧. **កថាខណ្ឌ ៧២**

***<u>អំណះអំណាងរបស់ ក.ស.ព</u>***៖ មេធាវីការពារក្តី "អះអាងថាអំពើរំលោភសេពសន្ថវៈពុំមែនជាបទល្មើសឡើយ។ ប៉ុន្តែផ្ទុយទៅវិញ ខ្លួនបានចាត់ទុកអំពើនេះថាជា "វង្វាន់ចាំបាច់សម្រាប់យុទ្ធជនដោយអនុលោមតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិគិតរហូតមកដល់ទសវត្សរ៍ឆ្នាំ ១៩៩០"។

***<u>សេចក្តីសង្កេត</u>***៖ នេះគឺជាការកត់សម្គាល់ពុំបានត្រឹមត្រូវអំពីគោលជំហររបស់មេធាវីការពារក្តី។ មេធាវីការពារក្តីពុំបានអះអាងដូចខាងលើឡើយ។ មេធាវីការពារក្តីបានដកស្រង់សម្តីរបស់អ្នកសង្កេតការណ៍មួយរូបដែលបានលើកឡើងថា៖ "នៅមុនទសវត្សរ៍ឆ្នាំ ១៩៩០ អំពើហិង្សាផ្លូវភេទនៅក្នុងពេលសង្គ្រាម កម្រមានភាពជាក់ស្តែងជាដុំកំភួនណាស់។ ប្រសិនបើអំពើហិង្សាផ្លូវភេទពុំមានភាពជាក់ស្តែង គេពុំផ្តល់ការយកចិត្តទុកដាក់ទៅលើអំពើនោះឡើយ។ ហើយប្រសិនបើអំពើនេះត្រូវបានគេផ្តល់ការយកចិត្តទុកដាក់វិញ គឺគេបានត្រឹមតែចាត់ទុកអំពើរំលោភសេពសន្ថវៈនេះ ថាជាបញ្ហាឯកជនប៉ុណ្ណោះ ឬមួយជាអនុផលនៃសង្គ្រាមដែលមិនអាចជៀសផុត ដែលជាវង្វាន់ចាំបាច់សម្រាប់យុទ្ធជន"[១៣]។ ការណ៍ដែលថាអំពើរំលោភសេពសន្ថវៈគឺជាវង្វាន់ចាំបាច់សម្រាប់យុទ្ធជនគិតរហូតមកដល់ទសវត្សរ៍ឆ្នាំ ១៩៩០ គឺពិតជាពុំមែនទស្សនៈរបស់មេធាវីការពារក្តីឡើយ។

៨. **កថាខណ្ឌ ៨១**

***<u>អំណះអំណាងរបស់ ក.ស.ព</u>***៖ ការដែលមេធាវីការពារក្តីលើកយកប្រភពច្បាប់នានាដូចមានរៀបរាប់ក្នុងមាត្រា ៣៨ (១) នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ("ICJ") មកធ្វើជាសំអាង គឺ "ពុំ

---

[១២] សេចក្តីសម្រេចលើសំណើរបស់ អៀង សារី ទាក់ទិននឹងការយកអង្គហេតុពីសំណុំរឿងលេខ ០០១ ដែលបានវិនិច្ឆ័យរួចហើយ និងអង្គហេតុបញ្ជាក់អំពីការដឹងឮជាទូទៅមកអនុវត្តក្នុងសំណុំរឿងលេខ ០០២, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១១, ឯកសារ E69/1, ទំព័រ ២-៣។

[១៣] Rhonda Copelon, *Gender Crimes as War Crimes: Integrating Crimes Against Women Into International Criminal Law*, 46 McGILL L.J. 217, 220 (2000).

ពាក់ព័ន្ធផ្ទាល់ទៅនឹងការណ៍ដែល អ.វ.ត.ក យកសាលដីការបស់តុលាការ ICTY មកប្រើប្រាស់ឡើយ ហើយក៏ពុំពាក់ព័ន្ធទៅនឹងការយកយុត្តិសាស្ត្រតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតូបនីយកម្ម មកធ្វើជាសំអាងទូទៅដែរ”។

***សេចក្តីសង្កេត៖*** អំណះអំណាងខាងលើនាំឱ្យមានការភ័ន្តច្រឡំ។ ប្រភពច្បាប់នានាដែលមានរៀបរាប់ក្នុងលក្ខន្តិកៈតុលាការ ICJ គឺពាក់ព័ន្ធផ្ទាល់ទៅនឹងការដែល អ.វ.ត.ក យកសាលដីការបស់តុលាការ ICTY និងសេចក្តីសម្រេចផ្សេងៗមកប្រើប្រាស់ ដោយហេតុថាបញ្ជីប្រភពឯកសារច្បាប់នានានៃលក្ខន្តិកៈតុលាការ ICJ បានទទួលឋានៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិរួចទៅហើយ ដែលបង្ហាញច្បាស់ត្រង់ចំណុចដែលថាមាត្រា ២១ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ មានរៀបរាប់អំពីប្រភពច្បាប់ទាំងអស់នេះ។ តាមពិត ក.ស.ព ខ្លួនឯង ក៏ធ្លាប់បានលើកយកបញ្ជីប្រភពឯកសារច្បាប់នៃលក្ខន្តិកៈតុលាការ ICJ នេះមកធ្វើជាសំអាងផងដែរ នៅក្នុងសារណារបស់ខ្លួននាពេលកន្លងមក[១៤]។

៩. **កថាខណ្ឌ ៨៥-៨៦**

***អំណះអំណាងរបស់ ក.ស.ព៖*** ក.ស.ព អះអាងថាទម្លាប់អនុវត្តន៍របស់រដ្ឋមួយចំនួនតូចដោយពុំមានការជំទាស់ពីរដ្ឋផ្សេងឯទៀត អាចបង្កើតបានជាច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលបានចាត់ទុកបទល្មើសរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ គំនិតនេះត្រូវបាន ក.ស.ព ដកស្រង់ចេញពីអត្ថបទមួយរបស់សាស្ត្រាចារ្យ Michael Akehurst និងសៀវភៅមួយរបស់សាស្ត្រាចារ្យ Malcolm Shaw។

***សេចក្តីសង្កេត៖*** នេះជាការសម្គាល់ទស្សនៈរបស់សាស្ត្រាចារ្យ Shaw ពុំបានត្រឹមត្រូវ និងជាការលើកយកច្បាប់មកបញ្ជាក់អះអាងពុំបានត្រឹមត្រូវ។ សាស្ត្រាចារ្យ Shaw បានគូសបញ្ជាក់ថា “រដ្ឋមួយចំនួនតូចអាចបង្កើតច្បាប់ទំនៀមទម្លាប់បាន ដរាបណារដ្ឋទាំងអស់នោះជាប់ពាក់ព័ន្ធស្និតរមួត

---

[១៤] “ឃ្លាថា ‘គោលការណ៍ច្បាប់ទូទៅដែលសហគមន៍ប្រជាជាតិបានទទួលស្គាល់” គឺសំដៅទៅដល់ប្រភពទី៣នៃច្បាប់អន្តរជាតិ ដែលមានចែងក្នុងមាត្រា ៣៨ នៃលក្ខន្តិកៈតុលាការ ICJ។ គោលការណ៍ទាំងនេះគឺជាប្រភពឯករាជ្យនៃច្បាប់អន្តរជាតិ ទើបបានគោលការណ៍ទាំងនេះខុសពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់អនុសញ្ញា”។ ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារ D427/1/17, កថាខណ្ឌ ១៦១។

ទៅនឹងបញ្ហាណាមួយ ទោះបីជាប់ពាក់ព័ន្ធដោយសារសម្បត្តិធនធាន និងសិទ្ធិអំណាចរបស់ពួកគេ ឬដោយសារទំនាក់ទំនងពិសេសរបស់ពួកគេជាមួយកម្មវត្ថុនៃទម្លាប់អនុវត្តន៍នោះក្តី"[១៥]។ ការថ្លែងដូចខាងលើរបស់សាស្ត្រាចារ្យ Shaw ពុំបានគាំទ្រអំណះអំណាងដែលថាបទរំលោភសេពសន្ថវៈក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចទទួលបានឋានៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ ដោយផ្អែកទៅតាមទម្លាប់អនុវត្តន៍របស់រដ្ឋមួយចំនួនតូចនោះ។ មិនមែនមានតែ "រដ្ឋមួយចំនួនតូច" ទេដែល "ជាប់ពាក់ព័ន្ធស្និតរមួត" ទៅនឹងបញ្ហារំលោភសេពសន្ថវៈ ក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ក្នុងនោះសាស្ត្រាចារ្យ Akehurst ដែល ក.ស.ព បានលើកយកមកធ្វើជាសំអាង បានពន្យល់ថា "ការពិតនៅដដែលគឺថាក្នុងករណីខ្លះ ទាល់តែមានទម្លាប់អនុវត្តន៍ច្រើនទើបអាចបង្កើតបានជាវិធានទំនៀមទម្លាប់"[១៦]។ ជាក់ស្តែង មានតែរដ្ឋដែលកំពុងដំណើរការកម្មវិធីអវកាសប៉ុណ្ណោះ នឹងបង្កើតបានជាទម្លាប់អនុវត្តន៍របស់រដ្ឋជាចាំបាច់ និង *ទស្សនៈគតិយុត្តិ* ស្តីពីច្បាប់អវកាស[១៧]។ នៅក្នុងកាលៈទេសៈទាំងអស់នេះ *ទស្សនៈគតិយុត្តិ* ដែលចងកាតព្វកិច្ចរដ្ឋចំនួនតែត្រឹម២ ងាយស្រួលបានការទទួលស្គាល់ជាងរដ្ឋច្រើន[១៨]។ ផ្ទុយទៅវិញ ទម្លាប់អនុវត្តន៍របស់រដ្ឋនិង *ទស្សនៈគតិយុត្តិ* របស់រដ្ឋទាំងអស់មានភាពពាក់ព័ន្ធ ដោយហេតុថារដ្ឋណាមួយក៏អាចកំណត់បទរំលោភសេពសន្ថវៈ ថាជាប្រភេទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលច្បាប់បានចែង ឬអាចរួមចំណែកឲ្យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប្រែក្លាយទៅជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ[១៩]។

### គ. សំណើរបស់ ក.ស.ព ស្តីពីសហឧក្រិដ្ឋកម្មរួម

១០. **កថាខណ្ឌ ៩៦**

---

[១៥] MALCOLM N. SHAW, INTERNATIONAL LAW 79 (Cambridge University Press 6th ed. 2008).

[១៦] Michael Akehurst, *Custom as a Source of International Law*, 47 BRITISH Y.B. INT'L L. 1, 19 (1974-75).

[១៧] សូមមើល MALCOLM N. SHAW, INTERNATIONAL LAW 75-76 (Cambridge University Press 2003) *citing* Bin Cheng, *United Nations Resolutions on Outer Space: 'Instant' International Customary Law*, 5 INDIAN J. INT'L L. 1, 23 (1965).

[១៨] សូមមើល MALCOLM N. SHAW, INTERNATIONAL LAW 75-76 (Cambridge University Press 2003).

[១៩] កន្លងមក មេធាវីការពារក្តីធ្លាប់បានឆ្លើយតបទៅនឹងអំណះអំណាងមួយស្រដៀងគ្នានេះរបស់ ក.ស.ព នៅពេល ក.ស.ព បានអះអាងថា "Grotian moment" បានកើតមាន ពាក់ព័ន្ធនឹងការបង្កើតសហឧក្រិដ្ឋកម្មរួម ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ *សូមមើល* សារណារបស់លោក អៀង សារី ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០, ឯកសារ D97/14/14, កថាខណ្ឌ ២១។

***អំណះអំណាងរបស់ ក.ស.ព៖*** ក.ស.ព "បានស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង ពិនិត្យមើលការវាយតម្លៃខាងក្រោម នៅក្នុងការវិភាគនាពេលចុងក្រោយអំពីនីត្យានុកូលភាពនៃការណ៍ដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសសម្រាប់លីបង់ យកសហឧក្រិដ្ឋកម្មរួមទម្រង់ទីIII មកអនុវត្ត"

***សេចក្តីសង្កេត៖*** អំណះអំណាងខាងលើនាំឱ្យមានការភ័ន្តច្រឡំ។ មេធាវីការពារក្តីកត់សម្គាល់ឃើញថាចៅក្រម Antonio Cassese គឺជាប្រធានតុលាការពិសេសសម្រាប់លីបង់។ គាត់ក៏ជាចៅក្រមមួយរូបក្នុងចំណោមចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង *Tadic* ដែលបានបង្កើតឡើងនូវគោលការណ៍ទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម។ ដោយយោងទៅលើតួនាទីរបស់សាស្ត្រាចារ្យ Cassese ក្នុងការបង្កើតគោលការណ៍សហឧក្រិដ្ឋកម្មរួម និងការណ៍ដែលគាត់បានជំរុញឥតឈប់ឈរឱ្យមានការទទួលស្គាល់សហឧក្រិដ្ឋកម្មរួម ថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ យើងគួរពិចារណាទៅលើការអះអាងរបស់ចៅក្រម Cassese អំពីហេតុផលក្នុងការទទួលស្គាល់សហឧក្រិដ្ឋកម្មរួមទម្រង់ទីIII ដោយយើងពិនិត្យទៅលើផលប្រយោជន៍របស់គាត់នៅក្នុងការរក្សាតម្កល់គោលការណ៍ទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម។ យើងពុំគួរយកចិត្តទុកដាក់ដល់ការអះអាងរបស់គាត់ឡើយ។ មេធាវីការពារក្តីធ្លាប់បានកត់សម្គាល់ឃើញថាការចាត់តាំងសាស្ត្រាចារ្យ Cassese ជា *អ្នកមិនមែនជាភាគីនៃរឿងក្តី (Amicus curiae)* លើបញ្ហាស្តីពីលទ្ធភាពរបស់ អ.វ.ត.ក ក្នុងការយកគោលការណ៍សហឧក្រិដ្ឋកម្មរួមមកអនុវត្ត ទាំងយើងដឹងថាគាត់ជាអ្នកទទួលបន្ទុកលើការបង្កើតឱ្យមានទម្រង់នៃការទទួលខុសត្រូវនេះនៅឯតុលាការ ICTY គឺមិនខុសពីការបញ្ជាឱ្យកញ្ជ្រោងទៅយាមទ្រុងមាន់ឡើយ ពោលគឺមិនខុសពីចាត់តាំងលោកសាស្ត្រាចារ្យ Cassese ឱ្យគាត់ទៅការពារគោលការណ៍សហឧក្រិដ្ឋកម្មរួម និងកេរដំណែលរបស់គាត់នៅក្នុងសទ្ធានុក្រមច្បាប់អន្តរជាតិ ឡើយ[២០]។

---

[២០] *សូមមើលរឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"*, ០០១/ ១៨-០៧-២០០៧-អវតក -កសចស (អបជ ០២), ពាក្យសុំរបស់ អៀង សារី សុំដកគុណវុឌ្ឍិសាស្ត្រាចារ្យ កាសេស៊ី(Cassese) និង សមាជិកមួយចំនួននៃក្រុមប្រឹក្សានិពន្ធនិង គណៈកម្មាធិការនិពន្ធ និងនៃទិនានុប្បវត្តិតុលាការព្រហ្មទណ្ឌអន្តរជាតិ ពីការដាក់សារណាជាលាយលក្ខណ៍អក្សររបស់ *អ្នកមិនជាភាគីនៃរឿងក្តី* ស្តីពីបញ្ហាសហឧក្រិដ្ឋកម្មរួមនៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៨, ឯកសារ D99/3/18, កថាខណ្ឌ ៤៧។ *សូមមើលផងដែរ* កថាខណ្ឌ ២៥-៣២ ដែលបង្ហាញច្បាស់អំពីមូលហេតុដែលសាស្ត្រាចារ្យ Cassese ពុំមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីធ្វើជា *អ្នកមិនមែនជាភាគីនៃ*

១១. **កថាខណ្ឌ ៩៧**

***អំណះអំណាងរបស់ ក.ស.ព៖*** "ទំនោរនាពេលបច្ចុប្បន្ននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ កំពុងប្រែប្រួលឃ្លាតចាកពីទ្រឹស្តី។ ពីមុនគេធ្លាប់អនុវត្តវិធីសាស្ត្របែបអត្តនោម័តិចំពោះភាពខុសគ្នារវាងការទទួលខុសត្រូវក្នុងនាមជាចារី និងការទទួលខុសត្រូវក្នុងនាមជាអ្នកសមគំនិត (ដូចជាសហឧក្រិដ្ឋកម្មរួម ជាដើម)។ ប៉ុន្តែសព្វថ្ងៃ គេងាកមកអនុវត្តវិធីសាស្ត្រ "គ្រប់គ្រងឧក្រិដ្ឋកម្ម" បែបសត្យានុម័តិវិញ។ "ទំនោរ" នេះទៀតសោត ក៏បានការឯកភាពគាំទ្រពីសំណាក់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងអ្នកស្រាវជ្រាវល្បីៗទៀតផង។ ប៉ុន្តែ "ចំណុចគួរពិចារណាទាំងអស់នេះពុំពាក់ព័ន្ធ" ឡើយទៅនឹងការពិចារណាថាតើ អ.វ.ត.ក អាចយកគោលការណ៍ទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមទម្រង់ទីIII មកអនុវត្តបានដែរឬយ៉ាងណានោះឡើយ។

***សេចក្តីសង្កេត៖*** នេះជាការលើកឡើងពុំត្រឹមត្រូវ។ ការរិះគន់របស់អ្នកស្រាវជ្រាវល្បីៗទៅលើគោលការណ៍សហឧក្រិដ្ឋកម្មរួមទម្រង់ទីIII ពុំមែនជារឿងថ្មីឡើយ។ អ្នកស្រាវជ្រាវនានាធ្លាប់បានអះអាងម្តងហើយម្តងទៀតថាអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង *Tadic* ជាអ្នកបង្កើតគោលការណ៍សហឧក្រិដ្ឋកម្មរួមទម្រង់ទីIIIនេះឡើង ហើយគោលការណ៍នេះពុំធ្លាប់ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ[២១]។

---

*រឿងក្តី* ក្នុងការឆ្លើយតបទៅនឹងសំណួររបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងលទ្ធភាពរបស់ អ.វ.ត.ក ក្នុងការយកសហឧក្រិដ្ឋកម្មរួមមកអនុវត្ត។

[២១] *សូមមើល* ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី III ជាទម្រង់មួយទៀតនៃការទទួលខុសត្រូវ និងសំណើសុំឱ្យមានសវនាការផ្ទាល់មាត់ដើម្បីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ E100/2, ឧបសម្ព័ន្ធ ៤, ដែលរាយនាមអ្នកស្រាវជ្រាវដែលបានរិះគន់គោលការណ៍សហឧក្រិដ្ឋកម្មរួមទាំងមូល ឬគោលការណ៍សហឧក្រិដ្ឋកម្មរួមទម្រង់ទីIII។ ក្នុងចំណោមអ្នកស្រាវជ្រាវទាំងនេះ ភាគច្រើនបានពន្យល់ថាគោលការណ៍សហឧក្រិដ្ឋកម្មរួមទម្រង់ទី III ពុំមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ ជាក់ស្តែង Kitti Jayangakula បានពន្យល់ថា "ប្រការសំខាន់ គោលការណ៍សហឧក្រិដ្ឋកម្មរួមទម្រង់ទីIII ពុំមានឋានៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលគួរទទួលស្គាល់ឡើយនៅពេលពាក់ព័ន្ធ ហើយជនជាប់ចោទពុំអាចដឹងមុនគ្រប់គ្រាន់អំពីគោលការណ៍ទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម ពិសេសគោលការណ៍សហឧក្រិដ្ឋកម្មរួមទម្រង់ទី III ថាជាបទល្មើស ហើយមានច្បាប់ចែងឡើយក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ហើយជនជាប់ចោទពុំបានដឹងគ្រប់គ្រាន់អំពីទម្រង់នៃការទទួលខុសត្រូវមួយនេះ នៅពេលពាក់ព័ន្ធ" Kitti Jayangakula, *Is the Doctrine of Joint Criminal Enterprise a Legitimate Mode of Individual Criminal Liability? A Study of the Khmer Rouge Trials*,

១២. **កថាខណ្ឌ ១០២**

***<u>អំណះអំណាងរបស់ ក.ស.ព៖</u>*** "ទោះបីច្បាប់កម្ពុជាចែងច្បាស់អំពីគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង* ក្តី ក៏ក្នុងកម្រិតជាតិ ពុំមានការអនុវត្តគោលការណ៍នេះផ្អែកលើយុត្តិសាស្ត្រពាក់ព័ន្ធនានាឡើយ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ" ដោយយោងទៅលើមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

***<u>សេចក្តីសង្កេត៖</u>*** នេះជាការសន្និដ្ឋានពុំត្រឹមត្រូវអំពីច្បាប់ជាធរមាននៅកម្ពុជា។ ក្នុងកម្រិតជាតិ និងអន្តរជាតិ បទដ្ឋាននៃគោលការណ៍នីត្យានុកូលភាព មិនដូចគ្នាទេ ដូច្នេះ ពុំមាន*ចន្លោះប្រហោង*ណាមួយ (*lacuna*) ដែលទាមទារឱ្យមានការពិចារណាទៅលើ "បទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ" ឡើយ។ មាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ មានចែងអំពីគោលការណ៍នីត្យានុកូលភាពនៅក្នុងន័យចង្អៀតជាងគោលការណ៍នីត្យានុកូលភាព ដែលមានចែងនៅក្នុងកម្រិតអន្តរជាតិ តាមរយៈកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[២២]។ ចំណុចថាតើ អ.វ.ត.ក អាចយកមាត្រា ៦ មកអនុវត្តបានដែរឬទេ ដើម្បីហាមឃាត់ការយកមកអនុវត្តនូវឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវដែលពុំមានចែងក្នុងច្បាប់ជាធរមាននៅកម្ពុជាពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ គឺជាបញ្ហាដែលអង្គជំនុំជម្រះសាលាដំបូងពុំទាន់សម្រេចនៅឡើយ[២៣]។ គោលការណ៍នីត្យានុកូលភាពគឺជាសិទ្ធិជាសារវ័ន្តមួយ (ខុសពីវិធាននីតិវិធី) ដែលពុំអនុញ្ញាតឱ្យមានការពិចារណាទៅលើបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ដោយអនុលោមតាមមាត្រា ៣៣ ថ្មី

---

(2010), ទំព័រ 68, *ដែលមាននៅលើគេហទំព័រ៖* http://lup.lub.lu.se/luur/download?func=downloadFile&recordOId=1693741&fileOId=1693742។

[២២] *សូមមើលជាឧទាហរណ៍,* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០, ឯកសារ D427/1/6, កថាខណ្ឌ ១០៦-១១០។

[២៣] *សូមមើល* សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី និងការជូនដំណឹងស្តីពីការមិនគោរពអនុស្សរណៈក្រៅផ្លូវការនានាពេលអនាគត ដែលត្រូវបានចេញជំនួសឱ្យសេចក្តីសម្រេចមានសំអាងហេតុរបស់តុលាការ ដែលជាកម្មវត្ថុបណ្តឹងឧទ្ធរណ៍, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារ E51/4, ដែលរៀបរាប់អំពីអញ្ញត្រកម្មរបស់លោក អៀង សារី ដោយអនុលោមតាមវិធាន ៨៩ ថា អ.វ.ត.ក ពុំមានសមត្ថកិច្ចយុត្តាធិការឡើយ ក្នុងការយកឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នានានៃការទទួលខុសត្រូវមកអនុវត្តចំពោះលោក អៀង សារី។

នៃច្បាប់ស្តីពីការបង្កើតឲ្យមាន អ.វ.ត.ក ឡើយ[២៤]។

សូមអង្គជំនុំជម្រះមេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី

ធ្វើនៅភ្នំពេញ ថ្ងៃទី **១៨ ខែ សីហា ឆ្នាំ ២០១១**

[២៤] *សូមមើល* មាត្រា២៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលចែងថា "វិធាន និងទម្រង់ការដែលមានលក្ខណៈសំខាន់នោះមានជាអាទិ៍គឺ វិធានទម្រង់ការដែលមានបំណងធានាការគោរពសិទ្ធិការពារខ្លួន"។